# ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចេញញត្តិគាំទ្រចំណាត់ការតាមផ្លូវច្បាប់ របស់ស្ថាប័នមានសមត្ថកិច្ចចាប់ខ្លួនបុគ្គល កឹម សុខា រឿងក្បត់ជាតិ

**ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ និងមន្ត្រីថ្នាក់ដឹកនាំនិយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧នេះ បានចេញញត្តិគាំទ្រយ៉ាងពេញទំហឹងទៅលើចំណាត់ការរបស់ស្ថាប័នសមត្ថកិច្ច ដែលចាប់ខ្លួនបុគ្គល កឹម សុខា ដែលបានឃុបឃិតជាមួយបក្ខពួក និងបរទេសមួយចំនួនជាសម្ងាត់ចង់ផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដឹកនាំដោយ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលជាទង្វើក្បត់ជាតិ ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ អធិបតេយ្យ និងឯករាជ្យភាពជាតិ របស់ប្រទេសកម្ពុជា។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមទទូចដល់ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ជាពិសេសស្ថាប័នតុលាការ សូមមេត្តាផ្តន្ទាទោសឲ្យបានធ្ងន់ធ្ងរ និងឲ្យបានសាកសមបំផុត ចំពោះអំពើក្បត់ជាតិដែលមិនអាចអត់ឱនឲ្យបាននេះ។

សូមបញ្ជាក់ថា លោក កឹម សុខា ត្រូវបានកម្លាំងសមត្ថកិច្ចចាប់ខ្លួននៅវេលាម៉ោងប្រមាណ ០០៖៣៥នាទីរំលងអាធ្រាត្រឈានចូលថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៧ នៅគេហដ្ឋានរបស់លោក ស្ថិតនៅក្នុងសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក្រោយពីមានការបែកធ្លាយវីដេអូក្បត់ជាតិបែបនេះ។

រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្តីថ្លែងការណ៍ភ្លាមៗ ក្រោយការចាប់ខ្លួននេះ ដោយបានចាត់ទុកកាយវិការ និងសកម្មភាពរបស់មេបក្សប្រឆាំងតាមរយៈការនិយាយដោយផ្ទាល់មាត់នៅក្នុងវីដេអូនេះថា ជាអំពើក្បត់ជាតិ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា ៤៤៣ (បទសន្ធិដ្ឋិភាពជាមួយបរទេស) ក្នុងផ្នែកទី១ ស្តីពីអំពើក្បត់ជាតិ និងអំពើចារកម្ម ជំពូកទី២ ស្តីពីការប៉ះពាល់សន្តិសុខនៃរដ្ឋ មាតិកាទី១ ស្តីពីអំពើក្បត់ជាតិ និងអំពើចារកម្មជំពូកទី២ ស្តីពីការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ មាតិកាទី១ ស្តីពីការប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ គន្ថីទី៤ ស្តីពីបទល្មើសប្រឆាំងនឹងជាតិ នៃក្រមព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា។

តាមរយៈសេចក្តីថ្លែងការណ៍នេះ រាជរដ្ឋាភិបាល បានអំពាវនាវដល់ប្រជាពលរដ្ឋរក្សាភាពស្ងប់ស្ងាត់ និងទុកករណីនេះជូនតុលាការ ដើម្បីចាត់ការបន្ត។

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល

*រាជរដ្ឋាភិបាល* សូមជម្រាបជូនសាធារណមតិជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០១៧ វេលាម៉ោង ០០:៣៥ នាទី នេះ ឈ្មោះ កឹម សុខា ត្រូវបានចាប់ខ្លួន ដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងបទល្មើសជាក់ស្តែង ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

*រាជរដ្ឋាភិបាល* សូមជម្រាបជូនថា តាមរយៈវីដេអូឃ្លីប ដែលត្រូវបានផ្សព្វផ្សាយដោយបណ្តាញ CBN (Cambodian Broadcasting Network) ដែលមានទីតាំងនៅអូស្ត្រាលី និងភស្តុតាងដទៃទៀតដែលអាជ្ញាធរមានសមត្ថកិច្ចប្រមូលបាន គឺបានបង្ហាញឱ្យឃើញច្បាស់អំពីផែនការសម្ងាត់នៃការឃុបឃិតគ្នារវាងឈ្មោះ កឹម សុខា និងបក្សពួក ជាមួយបរទេស ដែលធ្វើឱ្យប៉ះពាល់ដល់ព្រះរាជា-ណាចក្រកម្ពុជា។ អំពើនៃការឃុបឃិតគ្នាជាសម្ងាត់ខាងលើនេះ គឺជាអំពើក្បត់ជាតិ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា ៤៤៣ (បទសន្ទិដ្ឋិភាពជាមួយបរទេស) ក្នុងផ្នែកទី ១ ស្តីពីអំពើក្បត់ជាតិ និងអំពើចារកម្ម ជំពូកទី ២ ស្តីពីការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ មាតិកាទី១ ស្តីពីការប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ គន្ថីទី៤ ស្តីពីបទល្មើសប្រឆាំងនឹងជាតិ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ វីដេអូឃ្លីបខាងលើនេះ ក៏កំពុងតែបន្តផ្សព្វផ្សាយរហូតមកដល់ពេលនេះផងដែរ។ បច្ចុប្បន្ន ឈ្មោះ កឹម សុខា ស្ថិតនៅក្រោមការឃាត់ខ្លួន និងការចាត់ការតាមច្បាប់ ដោយស្ថាប័នមានសមត្ថកិច្ចនិងស្ថាប័នតុលាការ។

*រាជរដ្ឋាភិបាល* សូមអំពាវនាវឱ្យរក្សាភាពស្ងប់ស្ងាត់ និងទុកករណីនេះ ជូនតុលាការដើម្បីចាត់ការបន្តជាសមត្ថកិច្ចស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

អាស្រ័យហេតុនេះ សូមសាធារណមតិជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៧*


POLICE